# សេចក្តីប្រកាសព័ត៌មានរួម

# ការចោទប្រកាន់សកម្មជនគណបក្ស សមរង្ស៊ី និងប្រជាពលរដ្ឋនៅខេត្តកំពង់ធំ

# ពីបទភេរវកម្មជាការបន្ទាក់ទឹកចិត្តចូលរួមរបស់ប្រជាពលរដ្ឋ

អង្គការសង្គមស៊ីវិលដែលរួមមាន គណៈកម្មាធិការខុមហ្វ្រែល (COMFREL) និងគណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) មានក្តីព្រួយបារម្ភជាខ្លាំង ដោយបានទទួលដំណឹងថា សាលាដំបូងខេត្តកំពង់ធំបានធ្វើការចោទប្រកាន់ទៅលើសកម្មជនគណបក្ស សមរង្ស៊ី និងប្រជាពលរដ្ឋផ្សេងទៀត សរុបទាំងអស់ចំនួន ៤រូប ពីបទ "ភេរវកម្ម" ដោយបានចេញដីកាកោះឱ្យចូលខ្លួនកាលពីដើមខែកក្កដាឆ្នាំ ២០១០ កន្លងទៅនេះ។

គណៈកម្មាធិការទាំងពីរបានកត់សំគាល់ឃើញថា កាលពីឆ្នាំ២០០៤ កន្លងទៅ មានប្រជាពលរដ្ឋធ្វើការប្តឹងផ្តល់ និងបានសុំឱ្យធ្វើអន្តរាគមន៍ដោះស្រាយទៅលើករណីជនមិនស្គាល់មុខ ដែលបានធ្វើសកម្មភាពនៅពេលយប់ បង្កការភ័យខ្លាច ហើយដែលក្រោយមកពាក្យចចាមអារ៉ាម បានធ្វើឱ្យប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំចំនួនបី ក្នុងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។

ដោយសារពាក្យចចាមអារ៉ាមនេះ ទើបធ្វើឱ្យប្រជាពលរដ្ឋបាននាំគ្នាដាក់ពាក្យបណ្តឹងទៅកាន់អាជ្ញាធរមូលដ្ឋាន ដើម្បីសុំជួយអន្តរាគមន៍ឱ្យមានការស្រាវជ្រាវ និងការដោះស្រាយ។

គណៈកម្មាធិការទាំងពីរ យល់ឃើញថា ការចោទប្រកាន់របស់សាលាដំបូងខេត្តកំពង់ធំ ទៅលើសកម្មជនគណបក្ស សមរង្ស៊ី និងប្រជាពលរដ្ឋទាំងនេះ ពីបទ "ភេរវកម្ម" គឺជាការគំរាមកំហែងបំបាក់ស្មារតី និងធ្វើឱ្យប្រជាពលរដ្ឋមិនហ៊ានធ្វើកិច្ចសហការផ្តល់ព័ត៌មានទៅកាន់អាជ្ញាធរមានសមត្ថកិច្ចនោះឡើយ។ ម្យ៉ាងទៀត ការដែលសាលាដំបូងខេត្តកំពង់ធំប្រើប្រាស់មាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្មមកលើប្រជាពលរដ្ឋនៅក្នុងករណីនេះ គឺហាក់ដូចជាមានភាពមិនច្បាស់លាស់ និងមិនអនុវត្តន៍ត្រឹមត្រូវស្របទៅតាមច្បាប់ជាធរមានទេ។

គណៈកម្មាធិការខុមហ្វ្រែល និងគណៈកម្មាធិការប្រព្រឹត្តិកម្ម ស្នើសុំដល់សាលាដំបូងខេត្តកំពង់ធំ ឱ្យបញ្ឈប់ការចោទប្រកាន់ដោយមិនមានមូលដ្ឋានភស្តុតាងគ្រប់គ្រាន់ច្បាស់លាស់មកលើប្រជាពលរដ្ឋ ។

☏ **<u>សំរាប់ព័ត៌មានលំអិត សូមទាក់ទង:</u>**

| | | |
|---|---|---|
| លោក **គល់ បញ្ញា** | នាយកប្រតិបត្តិគណៈកម្មាធិការខុមហ្វ្រែល (COMFREL) | ទូរស័ព្ទលេខ: ០១២ ៩៤២ ០១៧ |
| លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| លោក **សុក សំអឿន** | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោកស្រី **ស៊ុន ចាន់សែន** | ប្រធានសមាគម KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |
| លោក **ចាន់ សុវ៉េត** | ប្រធានផ្នែកសិទ្ធិមនុស្សសមាគមអាដហុក (ADHOC) | ទូរស័ព្ទលេខ: ០១១ ២៧៤ ៩៥៩ |